តេឡេក្រាម ឯកសារមន្ត្រីសាធារណៈ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ០១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## គោលការណ៍និងនីតិវិធីនៃការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់មុខតំណែង នាយកនៃគ្រឹះស្ថានមធ្យមសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ០៦.នស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៧៣ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២២៤/១៥៥៩ ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀនកំរិតឧត្តម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀនកំរិតមូលដ្ឋាន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០១/៣៤១ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀនកំរិតបឋម
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៣១៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១០១ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៨២ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង
- បានឃើញអនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- បានឃើញអនុក្រឹត្យលេខ២១៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះ កំណត់អំពីគោលការណ៍និងនីតិវិធីនៃការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់មុខតំណែងនាយកនៃគ្រឹះស្ថានមធ្យមសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការដឹកនាំនិងគ្រប់គ្រងគ្រឹះស្ថាន។

**មាត្រា២ .-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ត្រីដែលពាក់ព័ន្ធនឹងការជ្រើសរើស ការវាយតម្លៃ ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់មុខតំណែងនាយកនៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ។

## ជំពូកទី២
## គោលការណ៍និងនីតិវិធី

**មាត្រា៣ .-**

ការតែងតាំងមុខតំណែងនាយកនៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ត្រូវផ្អែកលើមុខតំណែងទំនេរ លក្ខខណ្ឌចាំបាច់ និងលក្ខខណ្ឌទូទៅសម្រាប់មុខតំណែង ដើម្បីធានាបាននូវនិរន្តរភាពនិងប្រសិទ្ធភាពការងារក្នុងគ្រឹះស្ថាន។

**មាត្រា៤ .-**

ក្នុងករណីមុខតំណែងនាយកនៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ ឬគ្រឹះស្ថានបឋមសិក្សាសាធារណៈនៅទំនេរ ដោយមូលហេតុផ្សេងៗ ប្រធានការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ ត្រូវលើកសំណើដើម្បីរៀបចំនីតិវិធីនៃការជ្រើសរើសជូនអភិបាលក្រុង ស្រុក ខណ្ឌ។ ក្នុងរយៈពេលយ៉ាងយូរ១(មួយ)សប្តាហ៍បន្ទាប់ពីមុខតំណែងនាយកនៅទំនេរ អភិបាលក្រុង ស្រុក ខណ្ឌសាមី ត្រូវចេញលិខិតបង្គាប់ការចាត់តាំងនាយករងដែលមានក្របខ័ណ្ឌនិងឋានន្តរសក្តិខ្ពស់ជាងគេ ឱ្យបំពេញមុខងារជានាយកស្តីទី ប៉ុន្តែក្នុងករណីពុំមាននាយករងទេ អភិបាលក្រុង ស្រុក ខណ្ឌសាមី ត្រូវចេញលិខិតបង្គាប់ការចាត់តាំងលេខាធិការ ឬប្រធានក្រុមបច្ចេកទេសដែលមានក្របខ័ណ្ឌនិងឋានន្តរសក្តិខ្ពស់ជាងគេ ឱ្យបំពេញមុខងារជានាយកស្តីទី ដើម្បីដឹកនាំនិងគ្រប់គ្រងដំណើរការរបស់គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈរហូតដល់មានការតែងតាំងនាយកថ្មី។

អភិបាលក្រុង ស្រុក ខណ្ឌ ដោយមានការឯកភាពពីគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវលើកសំណើតែងតាំង ផ្លាស់ប្តូរ ឬបញ្ចប់មុខតំណែងនាយកនៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ជូនអភិបាលរាជធានី ខេត្ត ពិនិត្យនិងសម្រេច។

អភិបាលរាជធានី ខេត្ត ត្រូវរៀបចំកិច្ចប្រជុំគណៈអភិបាលរាជធានី ខេត្ត ដោយមានការចូលរួមពីអភិបាលក្រុង ស្រុក ខណ្ឌសាមី ប្រធានមន្ទីរអប់រំ យុវជន និងកីឡា និងប្រធានមន្ទីរមុខងារសាធារណៈ ដើម្បីពិភាក្សានិងពិនិត្យសម្រេចលើសំណើតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់មុខតំណែងនាយក ដោយដីការបស់អភិបាលរាជធានី ខេត្ត។

**មាត្រា៥ .-**

ក្នុងករណីនាយកនៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈមានកំហុសនិងការផ្តាំផ្តងក្នុងវិជ្ជាជីវៈ ក្នុងពេលបំពេញមុខងារ និងផ្អែកលើយោបល់របស់ក្រុមប្រឹក្សាវិន័យ ដោយអនុលោមតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ អភិបាលរាជធានី ក្រុង ស្រុក មានសិទ្ធិផ្អាកការងារពីមុខតំណែងនាយកដោយដីការបស់អភិបាលរាជធានី ក្រុង ស្រុក។ ការចាត់តាំងនាយកស្តីទី ការបញ្ចប់មុខតំណែង និងការតែងតាំងនាយកថ្មី ត្រូវអនុវត្តដោយអនុលោមតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា៦ ..**

លក្ខខណ្ឌសម្រាប់ការតែងតាំងនាយក យន្តការនៃការវាយតម្លៃបេក្ខជន នីតិវិធីនៃការជ្រើសរើសនិងការតែងតាំង ត្រូវអនុវត្តដោយអនុលោមតាមនិយាមនីតិវិធីប្រតិបត្តិសម្រាប់ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់មុខតំណែងនាយកនៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ដែលជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៧ ..**

ការកែសម្រួលនិយាមនីតិវិធីប្រតិបត្តិសម្រាប់ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់មុខតំណែងនាយកនៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ។

## ជំពូកទី៣
## ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

**មាត្រា៨ ..**

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវតាមដាន ត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់មុខតំណែងនាយកនៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ដោយអនុលោមតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

## ជំពូកទី៤
## ទណ្ឌកម្មខាងវិន័យ

**មាត្រា៩ ..**

ត្រូវចាត់ទុកថាបានប្រព្រឹត្តកំហុសនិងការផ្តាំផ្គងក្នុងវិជ្ជាជីវៈ ចំពោះមន្ត្រីដែលពាក់ព័ន្ធនឹងការជ្រើសរើស ការវាយតម្លៃ ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់មុខតំណែងនាយកនៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ដែលមិនអនុវត្តដោយអនុលោមតាមបទប្បញ្ញត្តិនៃអនុក្រឹត្យ និងនិយាមនីតិវិធីប្រតិបត្តិសម្រាប់ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់មុខតំណែងនាយកនៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ។

រាល់កំហុសនិងការផ្តាំផ្គងក្នុងវិជ្ជាជីវៈ ត្រូវអនុវត្តទណ្ឌកម្មខាងវិន័យថ្នាក់ទី២ ដូចមានកំណត់ក្នុងច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។ ការអនុវត្តទណ្ឌកម្មខាងវិន័យនេះ មិនរារាំងដល់ការចោទប្រកាន់ និងការផ្តន្ទាទោសខាងព្រហ្មទណ្ឌស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមានឡើយ។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**មាត្រា១០ ..**

លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការតែងតាំងនាយកនៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ត្រូវមានអានុភាពអនុវត្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

តេឡេក្រាម ឯកសារមន្ត្រីសាធារណៈ

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៨កើត ខែ បុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ មករា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ហ៊ុន ម៉ានី**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី ៦ ខែមករា ឆ្នាំ២០២៥ ស្តីពីគោលការណ៍និងនីតិវិធីនៃការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់មុខតំណែងនាយកនៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ។

# និយាមនីតិវិធីប្រតិបត្តិ
# សម្រាប់ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់មុខតំណែងនាយកនៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ

ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការដឹកនាំនិងគ្រប់គ្រងគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់មុខតំណែងនាយកនៃគ្រឹះស្ថានសិក្សាត្រូវអនុវត្តតាមនិយាមនីតិវិធីប្រតិបត្តិ ដូចខាងក្រោម៖

**១- លក្ខខណ្ឌសម្រាប់ការតែងតាំងនាយក**

ការតែងតាំងនាយកនៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ត្រូវអនុវត្តផ្អែកលើលក្ខខណ្ឌចាំបាច់ និងលក្ខខណ្ឌទូទៅ ដូចខាងក្រោម៖

**១.១- លក្ខខណ្ឌចាំបាច់៖**

បេក្ខជនដែលត្រូវសម្រាំង ដើម្បីយកមកវាយតម្លៃ ដាច់ខាតត្រូវតែបំពេញតាមលក្ខខណ្ឌចាំបាច់ ដូចតទៅ៖

- ជាមន្ត្រីរាជការក្របខ័ណ្ឌគ្រូបង្រៀនមានសញ្ញាបត្រយ៉ាងទាបកម្រិតមធ្យមសិក្សាទុតិយភូមិ បូកនឹងការបណ្តុះបណ្តាលផ្នែកគរុកោសល្យរយៈពេល២(ពីរ)ឆ្នាំ
- មានបទពិសោធការងារបង្រៀនយ៉ាងតិច៣(បី)ឆ្នាំ គិតត្រឹមថ្ងៃនៃការផ្សព្វផ្សាយព័ត៌មាននៃការជ្រើសរើសនាយក។

**១.២- លក្ខខណ្ឌទូទៅ**

**១.២.១- បំណិន** សំដៅដល់៖

- ការប្រមូលព័ត៌មាន ការសំយោគព័ត៌មាន ការបែងចែកព័ត៌មាន
- ការដឹកនាំអង្គប្រជុំ
- ការធ្វើបទបង្ហាញក្នុងអង្គប្រជុំ
- ការផ្តល់ព័ត៌មានត្រឡប់
- ការត្រិះរិះពិចារណា
- ការធ្វើសេចក្តីសម្រេចចិត្ត
- ការចរចា
- ការប្រាស្រ័យទាក់ទង
- ការដោះស្រាយបញ្ហា
- នវានុវត្តន៍។

**១.២.២- សមត្ថភាព** សំដៅដល់៖

- ការយល់ដឹងពីគោលនយោបាយ ច្បាប់ ផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត និងលិខិតរដ្ឋបាល
- ការអភិវឌ្ឍផែនការយុទ្ធសាស្ត្រសាលារៀន
- ការអភិវឌ្ឍផែនការប្រតិបត្តិប្រចាំឆ្នាំ
- ការរៀបចំផែនការប្រើប្រាស់គ្រូបង្រៀនប្រចាំឆ្នាំ
- ការរៀបចំសេវាម៉ោងបង្រៀន និងបំណែងចែកភារកិច្ចរបស់គ្រូបង្រៀន
- ការធ្វើអធិការកិច្ចផ្ទៃក្នុងសាលារៀន
- ការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុសាលារៀន
- ភាសាបរទេស អាចប្រើប្រាស់បានក្នុងការប្រាស្រ័យទាក់ទង
- ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា ទូរគមនាគមន៍ និងឌីជីថលកម្រិតមធ្យម
- ការបូកសរុបលទ្ធផលការងារ ការសរសេររបាយការណ៍ និងកំណត់ហេតុផ្សេងៗ។

**១.២.៣- បុគ្គលិកលក្ខណៈ និងលក្ខណសម្បត្តិផ្សេងៗទៀត** សំដៅដល់៖

- ភាពម៉ឺងម៉ាត់ ការប្តេជ្ញាចិត្តខ្ពស់ក្នុងការងារ និងស្មារតីទទួលខុសត្រូវក្នុងការងារ
- ការឧស្សាហ៍ព្យាយាម និងតស៊ូក្នុងការងារ
- ភាពស្មោះត្រង់ និងមានគោលជំហរច្បាស់លាស់
- ភាពយុត្តិធម៌ក្នុងការងារគ្រប់គ្រង និងការទទួលស្គាល់ការពិត
- ការទទួលខុសត្រូវខ្ពស់ក្នុងការងារ និងការផ្តល់ឱកាសដល់សហការី
- មនសិការវិជ្ជាជីវៈខ្ពស់ និងរក្សាការសម្ងាត់វិជ្ជាជីវៈ
- មានសាមគ្គីល្អ ការធ្វើការងារជាក្រុម និងគោរពឱ្យតម្លៃអ្នកដទៃនិងសហការី
- ស្វ័យកែលម្អនូវចំណុចខ្វះខាតជាប្រចាំ សីលធម៌រស់នៅល្អ និងសុខភាពល្អ
- ភាពប៉ិនប្រសប់ក្នុងការអនុវត្តការងារ និងអភិវឌ្ឍន៍សមត្ថភាពជាប្រចាំ
- ការគាំទ្រពីសហការី ការគាំទ្រពីសហគមន៍ ដោយផ្សារភ្ជាប់សាលារៀននិងសហគមន៍។

**១.២.៤- លទ្ធផលនៃការបង្រៀន និងការគ្រប់គ្រង** សំដៅដល់៖

- លទ្ធផលនៃការបង្រៀន/ការងារគ្រប់គ្រង
- ការឆ្លងវគ្គសិក្សា/បំប៉ន(ក្នុង ឬក្រៅប្រទេស) ដើម្បីពង្រឹងសមត្ថភាពជំនាញ។

លក្ខខណ្ឌចាំបាច់ និងលក្ខខណ្ឌទូទៅនៃការតែងតាំងនាយកនៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ត្រូវវាយតម្លៃនិងដាក់ពិន្ទុតាមតារាងវាយតម្លៃ ដូចមានកំណត់ក្នុងចំណុច ៣.៤ នៃនិយាមនេះ។

## ២- យន្តការនៃការវាយតម្លៃបេក្ខជន

ក្នុងករណីមុខតំណែងនាយកនៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ ឬគ្រឹះស្ថានបឋមសិក្សាសាធារណៈ នៅទំនេរ ដោយមូលហេតុផ្សេងៗ ប្រធានការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ ត្រូវលើកសំណើ ដើម្បីរៀបចំនីតិវិធីនៃការជ្រើសរើសជូនអភិបាលក្រុង ស្រុក ខណ្ឌ ក្នុងរយៈពេលយ៉ាងយូរ៥(ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ។

ផ្អែកលើសំណើរបស់ប្រធានការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ អភិបាលក្រុង ស្រុក ខណ្ឌសាមី ត្រូវចេញសេចក្តីសម្រេចបង្កើតគណៈកម្មការវាយតម្លៃ ដើម្បីពិនិត្យវាយតម្លៃ និងជ្រើសរើសបេក្ខជន សម្រាប់ស្នើតែងតាំងជានាយកក្នុងរយៈពេលយ៉ាងយូរ៥(ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ។

គណៈកម្មការវាយតម្លៃ មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - អភិបាលរងក្រុង ស្រុក ខណ្ឌ ទទួលបន្ទុកអប់រំ | ប្រធាន |
| - ប្រធានការិយាល័យគ្រប់គ្រងធនធានមនុស្ស/ប្រធានការិយាល័យរដ្ឋបាលនិងបុគ្គលិក | អនុប្រធាន |
| - ប្រធានការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ | សមាជិក |
| - នាយកក្នុងមុខតំណែង (ករណីមាននាយក) | សមាជិក |
| - មេឃុំ/ចៅសង្កាត់ | សមាជិក |
| - លេខាធិការ ឬប្រធានក្រុមបច្ចេកទេស ឬគ្រូបង្រៀនដែលមានក្របខ័ណ្ឌ ឋានន្តរសក្តិ និងថ្នាក់ខ្ពស់ជាងគេក្នុងសាលា ១(មួយ)រូប | សមាជិក។ |

សមាសភាពជាក់ស្តែងនៃគណៈកម្មការវាយតម្លៃ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់អភិបាលក្រុង ស្រុក ខណ្ឌសាមី។

គណៈកម្មការវាយតម្លៃ មានភារកិច្ចដូចតទៅ៖
- ផ្សព្វផ្សាយស្ដីពីការជ្រើសរើសនាយក
- ពិគ្រោះយោបល់ជាមួយបុគ្គលិកអប់រំនៃគ្រឹះស្ថានសិក្សាសាមី
- រៀបចំការទទួលពាក្យស្នើសុំឈរឈ្មោះជាបេក្ខជន និងរៀបចំសម្រាំងបញ្ជីឈ្មោះបេក្ខជនដែលបានបំពេញលក្ខខណ្ឌចាំបាច់សម្រាប់ការវាយតម្លៃ
- រៀបចំកិច្ចដំណើរការនៃការវាយតម្លៃ និងដាក់ពិន្ទុបេក្ខជនដោយផ្អែកលើលក្ខណសម្បត្តិស័ក្តិសមដែលបានកំណត់ក្នុងនិយាមនេះ ដោយត្រូវធ្វើឡើងជាសម្ងាត់
- បូកសរុបលទ្ធផលនៃការវាយតម្លៃ រៀបចំកំណត់ហេតុ របាយការណ៍វាយតម្លៃ និងដាក់ពិន្ទុ
- លើកសំណើសុំតែងតាំងនាយកទៅអភិបាលក្រុង ស្រុក ខណ្ឌ ដោយភ្ជាប់មកជាមួយនូវបញ្ជីរាយនាមមន្ត្រីស្នើសុំតែងតាំង ប្រវត្តិរូបសង្ខេបរបស់សាមីខ្លួន និងឯកសារពាក់ព័ន្ធសាមីខ្លួន ដូចជា វិញ្ញាបនបត្រ សញ្ញាបត្រជំនាញ លិខិតឯកត្តភូតពាក់ព័ន្ធនឹងមុខតំណែង ក្របខ័ណ្ឌ ឋានន្តរសក្តិ ថ្នាក់ចុងក្រោយ
- បំពេញភារកិច្ចផ្សេងទៀតស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន និងតាមការណែនាំរបស់អភិបាលក្រុង ស្រុក ខណ្ឌ។

## ៣- នីតិវិធីនៃការតែងតាំងនាយក

ក្នុងករណីគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ មាននាយកដែលត្រូវចូលនិវត្តន៍ អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវលើកសំណើជ្រើសរើសនិងតែងតាំងនាយកថ្មី ឱ្យបានរួចរាល់ក្នុងរយៈពេលយ៉ាងតិច ៣(បី)ខែ មុនដល់កាលកំណត់ចូលនិវត្តន៍។ ចំពោះគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ដែលមានមុខតំណែងនាយកនៅទំនេរ ដោយមូលហេតុផ្សេងៗ អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវលើកសំណើជ្រើសរើសនិងតែងតាំងនាយកថ្មី ឱ្យបានរួចរាល់យ៉ាងយូររយៈពេល ៣(បី)ខែ។

ក្នុងរយៈពេលយ៉ាងយូរ១ សប្ដាហ៍(មួយ)បន្ទាប់ពីមុខតំណែងនាយកនៅទំនេរ អភិបាលក្រុង ស្រុក ខណ្ឌសាមី ត្រូវចេញលិខិតបង្គាប់ការចាត់តាំង នាយករងដែលមានក្របខ័ណ្ឌនិងឋានន្តរសក្តិខ្ពស់ជាងគេ ឱ្យបំពេញមុខងារជានាយកស្ដីទី ប៉ុន្តែក្នុងករណីពុំមាននាយករងទេ អភិបាលក្រុង ស្រុក ខណ្ឌសាមី ត្រូវចេញលិខិតបង្គាប់ការចាត់តាំងលេខាធិការ ឬប្រធានក្រុមបច្ចេកទេសដែលមានក្របខ័ណ្ឌនិងឋានន្តរសក្តិខ្ពស់ជាងគេ ឱ្យបំពេញមុខងារជានាយកស្ដីទី ដើម្បីដឹកនាំនិងគ្រប់គ្រងដំណើរការរបស់គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ រហូតដល់មានការតែងតាំងនាយកថ្មី។

នីតិវិធីនៃការតែងតាំងនាយកនៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ត្រូវអនុវត្តតាមជំហានដូចខាងក្រោម៖

### ៣.១- ជំហានទី១៖ ការពិនិត្យលើតម្រូវការជ្រើសរើសនាយក

គណៈកម្មការវាយតម្លៃ ត្រូវប្រជុំពិនិត្យនិងវាយតម្លៃអំពីតម្រូវការជ្រើសរើសនាយក ដើម្បីរៀបចំផ្សព្វផ្សាយ។

### ៣.២- ជំហានទី២៖ ការផ្សព្វផ្សាយព័ត៌មានអំពីការជ្រើសរើសនាយក

ដោយផ្អែកលើតម្រូវការជ្រើសរើសនាយក គណៈកម្មការវាយតម្លៃត្រូវផ្សព្វផ្សាយព័ត៌មានអំពីការជ្រើសរើសនាយក ដល់ថ្នាក់ដឹកនាំ និងបុគ្គលិកអប់រំទាំងអស់ក្នុងគ្រឹះស្ថានសិក្សារបស់ខ្លួនឱ្យបានទូលំទូលាយ និងជាសាធារណៈសម្រាប់រយៈពេលយ៉ាងតិច ៣០(សាមសិប)ថ្ងៃ នៃថ្ងៃធ្វើការ។ ក្នុងករណីប្រញាប់ ការផ្សព្វផ្សាយត្រូវមានរយៈពេលយ៉ាងតិច ១៥(ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ។

គណៈកម្មការវាយតម្លៃ អាចប្រើប្រាស់គំរូពាក្យស្នើសុំឈរឈ្មោះជាបេក្ខជនសម្រាប់ការតែងតាំងនាយក តាមតារាងគំរូទី១៖ គំរូពាក្យស្នើសុំឈរឈ្មោះជាបេក្ខជនសម្រាប់ការតែងតាំងនាយក ដូចមានភ្ជាប់ជាមួយ។

### ៣.៣- ជំហានទី៣៖ ការទទួលពាក្យស្នើសុំ និងការសម្រាំងបញ្ជីឈ្មោះបេក្ខជន

គណៈកម្មការវាយតម្លៃ ត្រូវចាត់តាំងឱ្យមានការទទួលពាក្យស្នើសុំឈរឈ្មោះជាបេក្ខជនសម្រាប់ការជ្រើសរើសនិងតែងតាំងនាយក។ បេក្ខជនត្រូវបំពេញពាក្យស្នើសុំ និងភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធនានាដូចមានកំណត់ក្នុងគំរូពាក្យស្នើសុំ។

បន្ទាប់ពីផុតកំណត់នៃរយៈពេលផ្សព្វផ្សាយ គណៈកម្មការវាយតម្លៃ ត្រូវប្រជុំបូកសរុបនិងសម្រាំងបញ្ជីបេក្ខជនដែលមានគុណវុឌ្ឍិឆ្លើយតបនឹងលក្ខខណ្ឌចាំបាច់ និងលក្ខខណ្ឌទូទៅ ដូចមានកំណត់ក្នុងចំណុចទី១ខាងលើ ដើម្បីយកមកវាយតម្លៃ និងដាក់ពិន្ទុ ឱ្យបានរួចរាល់ក្នុងរយៈពេលយ៉ាងយូរ៥(ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ។

ក្នុងការសម្រាំងបញ្ជីបេក្ខជននេះ បើពិនិត្យឃើញថាពុំមានបេក្ខជនដែលកំពុងបម្រើការងារនៅក្នុងគ្រឹះស្ថានសិក្សារបស់ខ្លួនចាប់ពី ២(ពីរ)រូប ឡើងទៅ ដែលឆ្លើយតបទៅនឹងលក្ខខណ្ឌចាំបាច់ និងលក្ខខណ្ឌទូទៅដូចបានកំណត់ក្នុងនិយាមនេះ គណៈកម្មការវាយតម្លៃ ត្រូវស្នើសុំយោបល់ទៅអភិបាលក្រុង ស្រុក ខណ្ឌសាមីដើម្បីស្នើសុំជ្រើសរើសបេក្ខជនដែលមានលក្ខណសម្បត្តិស័ក្តិសមសម្រាប់ការតែងតាំងជានាយក ពីគ្រឹះស្ថានអប់រំផ្សេងទៀត ដើម្បីយកមកសម្រាំង និងពិនិត្យវាយតម្លៃ។

បេក្ខជនដែលត្រូវបានសម្រាំងមានចំនួនយ៉ាងតិច ២(ពីរ)រូប តាមគោលការណ៍កំណត់ដូចខាងក្រោម៖

- ក្នុងករណីបេក្ខជនដែលបានសម្រាំងមានបេក្ខភាពមកពីនាយករង ចំនួនចាប់ពី ២(ពីរ)រូប ឡើងទៅ គណៈកម្មការវាយតម្លៃ ត្រូវសម្រេចយកតែបេក្ខជនទាំងនោះប៉ុណ្ណោះ ដើម្បីយកមកធ្វើការវាយតម្លៃ និងដាក់ពិន្ទុ
- ក្នុងករណីបេក្ខជនដែលបានសម្រាំងនេះ មានបេក្ខភាពមកពីនាយករង តិចជាង ២(ពីរ)រូប គណៈកម្មការវាយតម្លៃ ត្រូវសម្រេចយកបេក្ខភាពបន្ថែមពីលេខាធិការ និងប្រធានក្រុមបច្ចេកទេស ដើម្បីយកមកធ្វើការវាយតម្លៃ និងដាក់ពិន្ទុ ដើម្បីសម្រាំងបេក្ខជនឱ្យបានយ៉ាងតិច ២(ពីរ)រូប
- ក្នុងករណីបេក្ខជនដែលបានសម្រាំងនេះ មានបេក្ខភាពមកពីនាយករង ឬលេខាធិការ ឬប្រធានក្រុមបច្ចេកទេសតិចជាង ២(ពីរ)រូប គណៈកម្មការវាយតម្លៃ ត្រូវសម្រេចយកបេក្ខជនបន្ថែមពីអនុប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន ដើម្បីយកមកធ្វើការវាយតម្លៃ និងដាក់ពិន្ទុ ដើម្បីសម្រាំងបេក្ខជនឱ្យបានយ៉ាងតិច ២(ពីរ)រូប។

### ៣.៤- ជំហានទី៤៖ ការវាយតម្លៃនិងការដាក់ពិន្ទុ

គណៈកម្មការវាយតម្លៃ ត្រូវរៀបចំកិច្ចប្រជុំដើម្បីវាយតម្លៃ និងដាក់ពិន្ទុដល់បេក្ខជនដែលមានឈ្មោះក្នុងបញ្ជីសម្រាំងបេក្ខជន ដោយប្រើប្រាស់តារាងវាយតម្លៃ ដែលបានកំណត់ក្នុងនិយាមនេះ។

សមាជិកម្នាក់ៗនៃគណៈកម្មការវាយតម្លៃ មានសិទ្ធិវាយតម្លៃនិងដាក់ពិន្ទុដល់បេក្ខជនគ្រប់រូប។ ចំពោះសមាជិកនៃគណៈកម្មការវាយតម្លៃ ដែលបានឈរឈ្មោះជាបេក្ខជន មិនត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងកិច្ចប្រជុំគណៈកម្មការវាយតម្លៃ និងគ្មានសិទ្ធិចូលរួមវាយតម្លៃ និងដាក់ពិន្ទុនេះឡើយ។

ក្នុងកិច្ចប្រជុំវាយតម្លៃនិងដាក់ពិន្ទុនេះ គណៈកម្មការវាយតម្លៃ អាចអញ្ជើញតំណាងគណៈកម្មការសាលា ឬអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមសង្កេតការណ៍។

ការវាយតម្លៃនិងដាក់ពិន្ទុដល់បេក្ខជន ត្រូវអនុវត្តតាមរយៈការពិនិត្យប្រវត្តិការងារ ព័ត៌មានផ្លូវការ ការសាកសួរ ការសម្ភាសន៍ ឬវិធីសាស្ត្រផ្សេងៗដែលចាំបាច់ ដោយផ្តល់ពិន្ទុផ្អែកតាមការកំណត់ដូចមានកំណត់ក្នុងតារាងគំរូទី២៖ តារាងវាយតម្លៃនិងដាក់ពិន្ទុបេក្ខជន ដូចមានភ្ជាប់ជាមួយ។

ប្រធានគណៈកម្មការវាយតម្លៃ ត្រូវប្រមូល វេចខ្ចប់ និងបូកសរុបលទ្ធផលនៃការវាយតម្លៃ និងដាក់ពិន្ទុរបស់គណៈកម្មការវាយតម្លៃ ដោយធានានូវសុវត្ថិភាព និងការសម្ងាត់ រួចលើកសំណើជូនអភិបាលក្រុង ស្រុក ខណ្ឌ ដើម្បីពិនិត្យនិងលើកសំណើបន្ត។

តេឡេក្រាម ឯកសារមន្ត្រីសាធារណៈ

**៣.៥- ជំហានទី៥៖ ការពិនិត្យនិងលើកសំណើតែងតាំង**

អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំកិច្ចប្រជុំគណៈអភិបាលរបស់ខ្លួន ដោយត្រូវមានការចូលរួមពីប្រធានគណៈកម្មការវាយតម្លៃ ប្រធានការិយាល័យអប់រំ យុវជន និងកីឡា ប្រធានការិយាល័យគ្រប់គ្រងធនធានមនុស្ស/ប្រធានការិយាល័យរដ្ឋបាលនិងបុគ្គលិក ដើម្បីពិនិត្យនិងសម្រេចលើលទ្ធផលនៃការវាយតម្លៃ និងដាក់ពិន្ទុរបស់គណៈកម្មការវាយតម្លៃ ក្នុងរយៈពេលយ៉ាងយូរ ១០(ដប់)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានសំណើ។

ក្នុងការពិនិត្យសម្រេចនេះ អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវធានាឱ្យមានការពិភាក្សា និងការពិគ្រោះយោបល់គ្នាដោយផ្អែកលើពិន្ទុនៃការវាយតម្លៃ ដើម្បីជ្រើសរើសយកបេក្ខជន១(មួយ)រូប ដែលមានលក្ខណសម្បត្តិស័ក្តិសមជាងគេសម្រាប់ស្នើសុំតែងតាំងជានាយក។

ក្នុងករណី ពុំអាចជ្រើសរើសបាននូវបេក្ខជនដែលកំពុងបម្រើការងារនៅក្នុងគ្រឹះស្ថានសិក្សាសាមីនីមួយៗដែលមានលក្ខណសម្បត្តិស័ក្តិសមសម្រាប់តែងតាំងជានាយក អភិបាលក្រុង ស្រុក ខណ្ឌ ដោយមានការពិភាក្សាជាមួយប្រធានការិយាល័យអប់រំ យុវជន និងកីឡា អាចពិនិត្យលទ្ធភាពជ្រើសរើសបេក្ខជនដែលមានលក្ខណសម្បត្តិស័ក្តិសមពីគ្រឹះស្ថានអប់រំផ្សេងទៀត ដើម្បីសម្រាំង វាយតម្លៃ និងស្នើសុំតែងតាំងជានាយកនៃគ្រឹះស្ថានបឋមសិក្សាសាធារណៈ និងមត្តេយ្យសិក្សាសាធារណៈ។

**៣.៦- ជំហានទី៦៖ ការតែងតាំងនាយក**

ផ្អែកលើលទ្ធផលនៃកិច្ចប្រជុំរបស់គណៈអភិបាល អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវលើកសំណើសុំតែងតាំងនាយកនៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងគ្រឹះស្ថានបឋមសិក្សាសាធារណៈ មកអភិបាលរាជធានី ខេត្ត និងចម្លងជូនប្រធានមន្ទីរអប់រំ យុវជន និងកីឡា និងប្រធានមន្ទីរមុខងារសាធារណៈ ដោយភ្ជាប់មកជាមួយនូវកំណត់ហេតុកិច្ចប្រជុំរបស់គណៈអភិបាលក្រុង ស្រុក ខណ្ឌ បញ្ជីរាយនាមបេក្ខជនដែលត្រូវស្នើសុំតែងតាំង ប្រវត្តិរូបសង្ខេបសាមីខ្លួន និងឯកសារពាក់ព័ន្ធនានា។

អភិបាលរាជធានី ខេត្ត ត្រូវរៀបចំកិច្ចប្រជុំគណៈអភិបាលរាជធានី ខេត្ត ដោយមានការចូលរួមពីអភិបាលក្រុង ស្រុក ខណ្ឌសាមី ប្រធានមន្ទីរអប់រំ យុវជន និងកីឡា និងប្រធានមន្ទីរមុខងារសាធារណៈ ដើម្បីពិភាក្សានិងពិនិត្យសម្រេចលើសំណើសុំតែងតាំងនាយក ដោយដីការបស់អភិបាលរាជធានី ខេត្ត ក្នុងរយៈពេលយ៉ាងយូរ ១៥(ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានសំណើ។

ក្នុងករណីមិនឯកភាពលើសំណើរបស់អភិបាលក្រុង ស្រុក ខណ្ឌ អភិបាលក្រុង ស្រុក ខណ្ឌសាមី ត្រូវរៀបចំនីតិវិធីជ្រើសរើសបេក្ខជនថ្មីស្របតាមបែបបទនិងនីតិវិធីដែលមានកំណត់ក្នុងនិយាមនេះ។

**៣.៧- ជំហានទី៧៖ ការប្រកាសចូលកាន់តំណែង**

អភិបាលក្រុង ស្រុក ខណ្ឌ ឬតំណាងគណៈអភិបាល ត្រូវរៀបចំពិធីប្រកាសចូលកាន់តំណែងនាយកថ្មី បន្ទាប់ពីដីកាតែងតាំងនាយកចូលជាធរមាន ក្នុងរយៈពេលយ៉ាងយូរ ១០(ដប់)ថ្ងៃ នៃថ្ងៃធ្វើការ។ នាយកថ្មីត្រូវចូលបំពេញមុខងារជាផ្លូវការបន្ទាប់ពីពិធីប្រកាសចូលកាន់តំណែង។

..............................................

**តារាងគំរូទី១៖ គំរូពាក្យស្នើសុំឈរឈ្មោះជាបេក្ខជនសម្រាប់ការតែងតាំងនាយក**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ......................កើតនៅថ្ងៃទី.......ខែ...........ឆ្នាំ..................មានក្របខ័ណ្ឌគ្រូបង្រៀនកម្រិត.......(.......) បច្ចុប្បន្នជា..........................................................................

**សូមគោរពជូន**
**លោក/លោកស្រីប្រធានគណៈកម្មការវាយតម្លៃនៃរដ្ឋបាល ក្រុង ស្រុក ខណ្ឌ**

**កម្មវត្ថុ** ៖ សំណើសុំឈរឈ្មោះជាបេក្ខជន ដើម្បីវាយតម្លៃស្នើសុំតែងតាំងជានាយក......................។

តបតាមកម្មវត្ថុខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមគោរពជម្រាបជូន **លោក/លោកស្រីប្រធាន** មេត្តាជ្រាបថា៖ ខ្ញុំបាទ/នាងខ្ញុំមានបំណងឈរឈ្មោះជាបេក្ខជន ដើម្បីវាយតម្លៃស្នើសុំតែងតាំងជា.............។

សូមភ្ជាប់មកជាមួយនូវ៖

- ប្រវត្តិរូបសង្ខេប ចំនួន ១(មួយ)ច្បាប់
- សញ្ញាបត្រ និងឯកសារពាក់ព័ន្ធ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **លោក/លោកស្រីប្រធាន** មេត្តាពិនិត្យលទ្ធភាពអនុញ្ញាតឱ្យរូបខ្ញុំបាទ/នាងខ្ញុំបានឈរឈ្មោះ ដោយសេចក្តីអនុគ្រោះ។

សូម **លោក/លោកស្រីប្រធាន** ទទួលនូវការគោរពដ៏ស្មោះពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ ខែ ឆ្នាំ.......... ព.ស.២៥......

....................ថ្ងៃទី ខែ ឆ្នាំ២០.....

**ហត្ថលេខា**

(ឈ្មោះសាមីជន)

## តារាងគំរូទី២៖ តារាងវាយតម្លៃនិងដាក់ពិន្ទុបេក្ខជន

| **១- កម្រិតបណ្តុះបណ្តាល៖ សញ្ញាបត្រនិងចំណេះដឹងឯកទេស** | **ពិន្ទុត្រូវផ្តល់តាមផ្នែក (ពិន្ទុសរុប.../២០)** |
|---|---|
| សញ្ញាបត្របណ្ឌិត | ៥ |
| សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ | ៣ |
| សញ្ញាបត្របរិញ្ញាបត្រ | ៣ |
| បរិញ្ញាបត្ររង ឬសញ្ញាបត្រសមមូល | ៣ |
| មធ្យមសិក្សាទុតិយភូមិបូក២ ឬសញ្ញាបត្រសមមូល | ៣ |
| ចំណេះដឹងឯកទេស៖ វិញ្ញាបនបត្រវិជ្ជាជីវៈនាយកសាលារៀន/គ្រូបង្រៀនល្អ | ៣ |
| **២- បំណិន៖** | (ពិន្ទុសរុប.../១០) |
| ២.១) ការប្រមូលព័ត៌មាន ការសំយោគព័ត៌មាន ការបែងចែកព័ត៌មាន | ១ |
| ២.២) ការដឹកនាំអង្គប្រជុំ | ១ |
| ២.៣) ការធ្វើបទបង្ហាញក្នុងអង្គប្រជុំ | ១ |
| ២.៤) ការផ្តល់ព័ត៌មានត្រឡប់ | ១ |
| ២.៥) ការត្រិះរិះពិចារណា | ១ |
| ២.៦) ការធ្វើសេចក្តីសម្រេចចិត្ត | ១ |
| ២.៧) ការចរចា | ១ |
| ២.៨) ការប្រាស្រ័យទាក់ទង | ១ |
| ២.៩) ការដោះស្រាយបញ្ហា | ១ |
| ២.១០) នវានុវត្តន៍/ការបង្កើតថ្មី | ១ |
| **៣- សមត្ថភាព (៣០ ពិន្ទុ)៖** | (ពិន្ទុសរុប.../៣០) |
| ៣.១) ការយល់ដឹងពីគោលនយោបាយ ច្បាប់ ផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត និងលិខិតរដ្ឋបាល ពាក់ព័ន្ធវិស័យអប់រំ យុវជន និងកីឡា | ៣ |
| ៣.២) ការអភិវឌ្ឍផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន | ៤ |
| ៣.៣) ការអភិវឌ្ឍផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន | ២ |
| ៣.៤) ការរៀបចំផែនការប្រើប្រាស់គ្រូបង្រៀនប្រចាំឆ្នាំ ផ្អែកតាមនិយាមប្រើប្រាស់បុគ្គលិក | ៣ |
| ៣.៥) ការរៀបចំសេវាម៉ោងបង្រៀន និងបំណែងចែកភារកិច្ចរបស់គ្រូបង្រៀន | ២ |
| ៣.៦) ការធ្វើអធិការកិច្ចផ្ទៃក្នុងសាលារៀន | ១ |
| ៣.៧) ការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុសាលារៀន | ៣ |
| ៣.៨) ភាសាបរទេស អាចប្រើប្រាស់បានក្នុងការប្រាស្រ័យទាក់ទង | ៥ |
| ៣.៩) ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា ទូរគមនាគមន៍ និងឌីជីថលក្នុងការបំពេញការងារប្រចាំថ្ងៃ ( Ms. Word Ms. Excell Ms. PowerPoint Telegram...) កម្រិតមធ្យម | ៥ |
| ៣.១០) បូកសរុបលទ្ធផលការងារ សរសេររបាយការណ៍ និងកំណត់ហេតុផ្សេងៗ | ២ |

| | |
|---|---|
| **៤- បុគ្គលិកលក្ខណៈ និងលក្ខណសម្បត្តិផ្សេងៗទៀត៖** | **(ពិន្ទុសរុប.../២០)** |
| ៤.១) ភាពម៉ឺងម៉ាត់ ប្ដេជ្ញាចិត្តខ្ពស់ និងស្មារតីទទួលខុសត្រូវក្នុងការងារ | ២ |
| ៤.២) ការឧស្សាហ៍ព្យាយាម និងតស៊ូក្នុងការងារ | ២ |
| ៤.៣) ភាពស្មោះត្រង់ និងមានគោលជំហរច្បាស់លាស់ | ២ |
| ៤.៤) ភាពយុត្តិធម៌ក្នុងការងារគ្រប់គ្រង និងការទទួលស្គាល់ការពិត | ២ |
| ៤.៥) ការទទួលខុសត្រូវខ្ពស់ក្នុងការងារ និងផ្ដល់ឱកាសដល់សហការី | ២ |
| ៤.៦) មនសិការវិជ្ជាជីវៈខ្ពស់ និងរក្សាការសម្ងាត់វិជ្ជាជីវៈ | ២ |
| ៤.៧) មានសាមគ្គីល្អ ការធ្វើការងារជាក្រុម និងគោរពឱ្យតម្លៃអ្នកដទៃ និងសហការី | ១ |
| ៤.៨) ស្វ័យកែលម្អនូវចំណុចខ្វះខាតជាប្រចាំ សីលធម៌រស់នៅល្អ និងសុខភាពល្អ | ១ |
| ៤.៩) ភាពប៉ិនប្រសប់ក្នុងការអនុវត្តការងារ និងអភិវឌ្ឍន៍សមត្ថភាពជាប្រចាំ | ២ |
| ៤.១០) ការគាំទ្រពីសហការី និងការគាំទ្រពីសហគមន៍ | ២ |
| ៤.១១) ការចូលរួមអនុវត្តការងារសង្គម(មានការបញ្ជាក់ពីក្រុមប្រឹក្សាឃុំសង្កាត់ ឬគណៈអភិបាលក្រុង ស្រុក ខណ្ឌ) | ២ |
| **៥- លទ្ធផល(បង្រៀន/គ្រប់គ្រង)/ចូលរួមវគ្គសិក្សា (១០ ពិន្ទុ)៖** | **(ពិន្ទុសរុប.../១០)** |
| ៥.១) លទ្ធផលនៃការបង្រៀន/ការងារគ្រប់គ្រង | ៧ |
| ៥.២) ការឆ្លងវគ្គសិក្សា/បំប៉ន(ក្នុង ឬក្រៅប្រទេស) ដើម្បីពង្រឹងសមត្ថភាពជំនាញ | ៣ |
| **៦- បទពិសោធការងារ** | **(ពិន្ទុសរុប.../១០)** |
| ៦.១) មានបទពិសោធជានាយករង (១០ ពិន្ទុ)៖ | |
| - ក្រោម ៣ឆ្នាំ | ២ |
| - ចាប់ពី ៣ឆ្នាំ ដល់ ៥ឆ្នាំ | ៤ |
| - ចាប់ពី ៦ឆ្នាំ ដល់ ១៥ឆ្នាំ | ៦ |
| - ចាប់ពី ១៦ឆ្នាំ ដល់ ២០ឆ្នាំ | ៨ |
| - លើសពី ២០ឆ្នាំ | ១០ |
| ៦.២) មានបទពិសោធជាលេខាធិការ/ប្រធានក្រុមបច្ចេកទេស/អនុប្រធានក្រុមបច្ចេកទេស/គ្រូបង្រៀន (ពិន្ទុសរុប ៨ ពិន្ទុ) (សម្រាប់ករណីបេក្ខជន មិនធ្លាប់ជានាយករង)៖ | |
| - ចាប់ពី ៣ឆ្នាំ ដល់ ៦ឆ្នាំ | ២ |
| - ចាប់ពី ៧ឆ្នាំ ដល់ ១៦ឆ្នាំ | ៤ |
| - ចាប់ពី ១៦ឆ្នាំ ដល់ ២០ឆ្នាំ | ៦ |
| - លើសពី ២០ឆ្នាំ | ៨ |

| | | |
|---|---|---|
| **ឈ្មោះសាមីជន៖**<br>**ឈ្មោះអ្នកវាយតម្លៃ៖** | ..........................................................<br>.......................................................... | **ពិន្ទុសរុប (១០០)** |

**សម្គាល់៖**

- ពិន្ទុសរុប ១០០ ល្អណាស់
- ពិន្ទុសរុបចាប់ពី ៩០ ដល់ ៩៩ ល្អ
- ពិន្ទុសរុបចាប់ពី ៧០ ដល់ ៨៩ ល្អបង្គួរ
- ពិន្ទុសរុបតូចជាង ៧០ មធ្យម។
- បេក្ខជនជានារី ត្រូវបានផ្ដល់អាទិភាពសម្រាប់ការតែងតាំងជានាយកនៃគ្រឹះស្ថានបឋមសិក្សា និងមត្តេយ្យសិក្សាសាធារណៈ។